ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៩១ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារបច្ចេកទេសជំរុញនិងគាំទ្រសេដ្ឋកិច្ចឌីជីថល និងរៀបចំកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤១២ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២១/៥៦៤ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល
- បានឃើញអនុក្រឹត្យលេខ ២២០ អនក្រ.បក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសជំរុញនិងគាំទ្រសេដ្ឋកិច្ចឌីជីថលនិងរៀបចំកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថល ចំនួន១៣(ដប់បី) ដូចខាងក្រោម៖

- ក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- ក្រុមការងារបច្ចេកទេសទទួលបន្ទុកប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិក
- ក្រុមការងារបច្ចេកទេសទទួលបន្ទុកសារពើពន្ធឌីជីថល

- ក្រុមការងារបច្ចេកទេសទទួលបន្ទុកបច្ចេកវិទ្យាហិរញ្ញវត្ថុនិងនិយ័តកម្មធុរកិច្ចឌីជីថល
- ក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្រួលពាណិជ្ជកម្មឌីជីថល
- ក្រុមការងារបច្ចេកទេសទទួលបន្ទុកការទូទាត់សងប្រាក់តាមប្រព័ន្ធឌីជីថល
- ក្រុមការងារបច្ចេកទេសទទួលបន្ទុកពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- ក្រុមការងារបច្ចេកទេសទទួលបន្ទុកអត្តសញ្ញាណឌីជីថល
- ក្រុមការងារបច្ចេកទេសទទួលបន្ទុកលំហូរកម្លាំងពលកម្មជំនាញនិងការបណ្តុះបណ្តាលជំនាញឌីជីថល
- ក្រុមការងារបច្ចេកទេសទទួលបន្ទុកការកសាងធនធានមនុស្សឌីជីថល
- ក្រុមការងារបច្ចេកទេសទទួលបន្ទុកការលើកកម្ពស់និងការជំរុញបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍
- ក្រុមការងារបច្ចេកទេសទទួលបន្ទុកសុវត្ថិភាពឌីជីថល សន្តិសុខសាយប័រ និងអភិបាលកិច្ចទិន្នន័យ
- ក្រុមការងារបច្ចេកទេសទទួលបន្ទុកហេដ្ឋារចនាសម្ព័ន្ធនិងការតភ្ជាប់ឌីជីថល។

**ប្រការ២.-**

ក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល មានអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថលជាលេខាធិការដ្ឋាន។

ក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល មានភារកិច្ចដូចខាងក្រោម៖

- បំពេញមុខងារជាសេនាធិការបច្ចេកទេសបូកសរុបកណ្តាលឱ្យក្រុមការងារបច្ចេកទេសផ្សេងទៀត
- ផ្តល់ទស្សនាទាននិងមគ្គុទ្ទេសក៍ណែនាំ ជំរុញ និងគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលនិងរៀបចំកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថល
- សហការនិងសម្របសម្រួលការងាររបស់ក្រុមការងារបច្ចេកទេសផ្សេងទៀត ដែលមានលក្ខណៈអន្តរវិស័យ
- ពិនិត្យនិងតាមដានវឌ្ឍនភាពការងារ សមិទ្ធកម្ម និងបញ្ហាប្រឈមរបស់ក្រុមការងារបច្ចេកទេសផ្សេងទៀត
- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម និងបញ្ហាប្រឈមរបស់ក្រុមការងារបច្ចេកទេសផ្សេងទៀត ព្រមទាំងលើកសំណើដំណោះស្រាយតាមការចាំបាច់
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល។

**ប្រការ៣.-**

ក្រុមការងារបច្ចេកទេសទទួលបន្ទុកប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិក ត្រូវដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រុមការងារបច្ចេកទេសទទួលបន្ទុកប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិក មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំនិងអនុវត្តផែនការនិងកម្មវិធីថ្នាក់ជាតិសម្រាប់ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិក
- ជំរុញការស្រាវជ្រាវអំពីប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិក

- ចូលរួមផ្តល់យោបល់និងរៀបចំកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថលពាក់ព័ន្ធនឹងប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិក
- ផ្តល់កិច្ចសហការជាមួយនឹងក្រុមការងារបច្ចេកទេសផ្សេងទៀត ក្នុងការបំពេញការងារដែលមានលក្ខណៈអន្តរវិស័យ ដោយមានការសម្របសម្រួលពីក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- រៀបចំ បូកសរុប និងផ្តល់របាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម និងបញ្ហាប្រឈមជូនក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុកប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិក។

**ប្រការ៤.-**

ក្រុមការងារបច្ចេកទេសទទួលបន្ទុកសារពើពន្ធឌីជីថល ត្រូវដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្រុមការងារបច្ចេកទេសទទួលបន្ទុកសារពើពន្ធឌីជីថល មានភារកិច្ចដូចខាងក្រោម៖

- សិក្សានិងកំណត់អត្តសញ្ញាណកម្មនិងកម្មវត្ថុសារពើពន្ធឌីជីថលសម្រាប់កម្ពុជា
- ជំរុញការស្រាវជ្រាវអំពីក្របខណ្ឌគោលនយោបាយ បទពិសោធ ឧត្តមានុវត្តន៍ និងនិន្នាការនៃការកសាងនិងការអនុវត្តសារពើពន្ធឌីជីថល
- ជំរុញការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តសារពើពន្ធឌីជីថលរបស់ក្រុមហ៊ុននិងសហគ្រាស ដើម្បីធានាបានការប្រកួតប្រជែងដោយស្មោះត្រង់និងយុត្តិធម៌ ព្រមទាំងការមិនបំពេញកាតព្វកិច្ចសារពើពន្ធឌីជីថល
- ជំរុញការផ្សព្វផ្សាយអំពីសារពើពន្ធឌីជីថល
- ពិនិត្យ សិក្សា និងលើកសំណើរៀបចំនិង/ឬធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតពាក់ព័ន្ធនឹងសារពើពន្ធឌីជីថល
- ចូលរួមផ្តល់យោបល់និងរៀបចំកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថលពាក់ព័ន្ធនឹងសារពើពន្ធឌីជីថល
- ផ្តល់កិច្ចសហការជាមួយនឹងក្រុមការងារបច្ចេកទេសផ្សេងទៀត ក្នុងការបំពេញការងារដែលមានលក្ខណៈអន្តរវិស័យ ដោយមានការសម្របសម្រួលពីក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- រៀបចំ បូកសរុប និងផ្តល់របាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម និងបញ្ហាប្រឈមជូនក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុកសារពើពន្ធឌីជីថល។

**ប្រការ៥.-**

ក្រុមការងារបច្ចេកទេសទទួលបន្ទុកបច្ចេកវិទ្យាហិរញ្ញវត្ថុនិងនិយ័តកម្មធុរកិច្ចឌីជីថល ត្រូវដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រុមការងារបច្ចេកទេសទទួលបន្ទុកបច្ចេកវិទ្យាហិរញ្ញវត្ថុនិងនិយ័តកម្មធុរកិច្ចឌីជីថល មានភារកិច្ចដូចខាងក្រោម៖

- ជំរុញការស្រាវជ្រាវ ការវាយតម្លៃ ការសហការ និងការសម្របសម្រួលការងារពាក់ព័ន្ធនឹងការកសាង ការអភិវឌ្ឍ និងការធ្វើនិយ័តកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារនិងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដែលរួមបញ្ចូលនូវហិរញ្ញវត្ថុមីក្រូការនិងបច្ចេកវិទ្យាដែលកំពុងលេចឡើង
- ជំរុញនិងគាំទ្រដល់ការអភិវឌ្ឍនិយ័តកម្មធុរកិច្ចឌីជីថល
- ចូលរួមផ្តល់យោបល់និងរៀបចំកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថលពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ និងនិយ័តកម្មធុរកិច្ចឌីជីថល
- ផ្តល់កិច្ចសហការជាមួយនឹងក្រុមការងារបច្ចេកទេសផ្សេងទៀត ក្នុងការជំរុញការងារដែលមានលក្ខណៈអន្តរវិស័យ ដោយមានការសម្របសម្រួលពីក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- រៀបចំ បូកសរុប និងផ្តល់របាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម និងបញ្ហាប្រឈមជូនក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុកបច្ចេកវិទ្យាហិរញ្ញវត្ថុនិងនិយ័តកម្មធុរកិច្ចឌីជីថល។

**ប្រការ៦.-**

ក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្រួលពាណិជ្ជកម្មឌីជីថល ត្រូវដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្រួលពាណិជ្ជកម្មឌីជីថល មានភារកិច្ចដូចខាងក្រោម៖

- ជំរុញនិងគាំទ្រដល់ការសម្រួលពាណិជ្ជកម្មគ្មានក្រដាសស្នាម
- ជំរុញអន្តរប្រតិបត្តិការនៃប្រព័ន្ធបញ្ជរតែមួយជាតិជាមួយនឹងប្រព័ន្ធឌីជីថលនៅក្នុងបរិការណ៍តំបន់និងសកល
- សិក្សាអំពីនីតិវិធីនិងពន្លឿនដំណើរការពន្ធគយ
- សិក្សានិងជំរុញការបើកចំហរឯកសារជាទម្រង់ឌីជីថលសំដៅសម្រួលពាណិជ្ជកម្មឌីជីថល
- ចូលរួមផ្តល់យោបល់និងរៀបចំកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថលពាក់ព័ន្ធនឹងការសម្រួលពាណិជ្ជកម្មឌីជីថល
- ផ្តល់កិច្ចសហការជាមួយនឹងក្រុមការងារបច្ចេកទេសផ្សេងទៀត ក្នុងការជំរុញការងារដែលមានលក្ខណៈអន្តរវិស័យ ដោយមានការសម្របសម្រួលពីក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- រៀបចំ បូកសរុប និងផ្តល់របាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម និងបញ្ហាប្រឈមជូនក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល

- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្រួលពាណិជ្ជកម្មឌីជីថល។

**ប្រការ៧.**

ក្រុមការងារបច្ចេកទេសទទួលបន្ទុកការទូទាត់សងប្រាក់តាមប្រព័ន្ធឌីជីថល ត្រូវដឹកនាំដោយធនាគារជាតិនៃកម្ពុជា។

ក្រុមការងារបច្ចេកទេសទទួលបន្ទុកការទូទាត់សងប្រាក់តាមប្រព័ន្ធឌីជីថល មានភារកិច្ចដូចខាងក្រោម៖

- ជំរុញនិងគាំទ្រដល់ការទូទាត់សងប្រាក់តាមប្រព័ន្ធឌីជីថលក្នុងស្រុកនិងការទូទាត់ឆ្លងកាត់ព្រំដែន
- ជំរុញការសិក្សាអំពីតម្រូវការនិយ័តកម្មនិងបទប្បញ្ញត្តិក្នុងការតភ្ជាប់ជាមួយនឹងបណ្តាប្រទេសក្នុងបរិការណ៍តំបន់និងសកល
- ចូលរួមផ្តល់យោបល់និងរៀបចំកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថលពាក់ព័ន្ធនឹងការទូទាត់សងប្រាក់តាមប្រព័ន្ធឌីជីថល
- ផ្តល់កិច្ចសហការជាមួយនឹងក្រុមការងារបច្ចេកទេសផ្សេងទៀត ក្នុងការជំរុញការងារដែលមានលក្ខណៈអន្តរវិស័យ ដោយមានការសម្របសម្រួលពីក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- រៀបចំ បូកសរុប និងផ្តល់របាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម និងបញ្ហាប្រឈមជូនក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុកការទូទាត់សងប្រាក់តាមប្រព័ន្ធឌីជីថល។

**ប្រការ៨.**

ក្រុមការងារបច្ចេកទេសទទួលបន្ទុកពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវដឹកនាំដោយក្រសួងពាណិជ្ជកម្ម។

ក្រុមការងារបច្ចេកទេសទទួលបន្ទុកពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានភារកិច្ចដូចខាងក្រោម៖

- ជំរុញនិងគាំទ្រដល់ការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- ជំរុញនិងតាមដានការអនុវត្តដោយស្មើភាពនិងយុត្តិធម៌ចំពោះផលិតផលនិងសេវាឌីជីថល
- ជំរុញការសម្រួលនីតិវិធីនៃការដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែន
- សិក្សានិងរៀបចំយន្តការដោះស្រាយវិវាទសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែន
- ចូលរួមផ្តល់យោបល់និងរៀបចំកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថលពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- ផ្តល់កិច្ចសហការជាមួយនឹងក្រុមការងារបច្ចេកទេសផ្សេងទៀត ក្នុងការជំរុញការងារដែលមានលក្ខណៈអន្តរវិស័យ ដោយមានការសម្របសម្រួលពីក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល

- រៀបចំ បូកសរុប និងផ្តល់របាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម និងបញ្ហាប្រឈមជូនក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុកពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**ប្រការ៩.-**

ក្រុមការងារបច្ចេកទេសទទួលបន្ទុកអត្តសញ្ញាណឌីជីថល ត្រូវដឹកនាំដោយក្រសួងមហាផ្ទៃ។

ក្រុមការងារបច្ចេកទេសទទួលបន្ទុកអត្តសញ្ញាណឌីជីថល មានភារកិច្ចដូចខាងក្រោម៖

- ជំរុញនិងគាំទ្រដល់ការអភិវឌ្ឍអត្តសញ្ញាណឌីជីថល
- ជំរុញការរៀបចំក្របខណ្ឌអន្តរប្រតិបត្តិការបច្ចេកទេសពាក់ព័ន្ធនឹងអត្តសញ្ញាណឌីជីថល
- ជំរុញការស្រាវជ្រាវអំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតពាក់ព័ន្ធនឹងអត្តសញ្ញាណឌីជីថល
- ជំរុញការទទួលស្គាល់ទៅវិញទៅមកពាក់ព័ន្ធនឹងការផ្លាស់ប្តូរនិងការការពារទិន្នន័យឆ្លងកាត់ព្រំដែន
- ចូលរួមផ្តល់យោបល់និងរៀបចំកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថលពាក់ព័ន្ធនឹងអត្តសញ្ញាណឌីជីថល
- ផ្តល់កិច្ចសហការជាមួយនឹងក្រុមការងារបច្ចេកទេសផ្សេងទៀត ក្នុងការជំរុញការងារដែលមានលក្ខណៈអន្តរវិស័យ ដោយមានការសម្របសម្រួលពីក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- រៀបចំ បូកសរុប និងផ្តល់របាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម និងបញ្ហាប្រឈមជូនក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុកអត្តសញ្ញាណឌីជីថល។

**ប្រការ១០.-**

ក្រុមការងារបច្ចេកទេសទទួលបន្ទុកហំប្រកម្លាំងពលកម្មជំនាញនិងការបណ្តុះបណ្តាលជំនាញឌីជីថល ត្រូវដឹកនាំដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ក្រុមការងារបច្ចេកទេសទទួលបន្ទុកហំប្រកម្លាំងពលកម្មជំនាញនិងការបណ្តុះបណ្តាលជំនាញឌីជីថល មានភារកិច្ចដូចខាងក្រោម៖

- ជំរុញនិងគាំទ្រដល់ហំប្រកម្លាំងពលកម្មជំនាញនិងការបណ្តុះបណ្តាលជំនាញឌីជីថល
- សិក្សានិងរៀបចំយន្តការគាំទ្រដល់ហំប្រកម្លាំងពលកម្មឌីជីថល
- សិក្សានិងរៀបចំយន្តការគាំទ្រដល់ការបំពេញការងារពីចម្ងាយសម្រាប់អ្នកមានទេពកោសល្យឌីជីថលនិងសហគ្រិនឌីជីថល
- ចូលរួមផ្តល់យោបល់និងរៀបចំកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថលពាក់ព័ន្ធនឹងហំប្រកម្លាំងពលកម្មជំនាញនិងការបណ្តុះបណ្តាលជំនាញឌីជីថល



ꟸW

- ផ្តល់កិច្ចសហការជាមួយនឹងក្រុមការងារបច្ចេកទេសផ្សេងទៀត ក្នុងការជំរុញការងារដែលមានលក្ខណៈអន្តរវិស័យ ដោយមានការសម្របសម្រួលពីក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- រៀបចំ បូកសរុប និងផ្តល់របាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម និងបញ្ហាប្រឈមជូនក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុករំហូរកម្លាំងពលកម្មជំនាញនិងការបណ្តុះបណ្តាលជំនាញឌីជីថល។

**ប្រការ១១.-**

ក្រុមការងារបច្ចេកទេសទទួលបន្ទុកការកសាងធនធានមនុស្សឌីជីថល ត្រូវដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា។

ក្រុមការងារបច្ចេកទេសទទួលបន្ទុកការកសាងធនធានមនុស្សឌីជីថល មានភារកិច្ចដូចខាងក្រោម៖

- ជំរុញនិងគាំទ្រដល់ការកសាងធនធានមនុស្សឌីជីថល
- រៀបចំក្របខណ្ឌ យន្តការ គោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីបណ្តុះបណ្តាលនិងបង្កើនសមត្ថភាព ជំនាញ និងគុណវុឌ្ឍិផ្នែកឌីជីថល ស្របតាមឧត្តមានុវត្តន៍និងនិន្នាការនៃការកសាងធនធានមនុស្សឌីជីថល ក្នុងបរិការណ៍តំបន់និងសកល
- ជំរុញនិងគាំទ្រដល់ការសិក្សាពេញមួយជីវិតក្នុងវិស័យឌីជីថល
- ចូលរួមផ្តល់យោបល់និងរៀបចំកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថលពាក់ព័ន្ធនឹងការកសាងធនធានមនុស្សឌីជីថល
- ផ្តល់កិច្ចសហការជាមួយនឹងក្រុមការងារបច្ចេកទេសផ្សេងទៀត ក្នុងការជំរុញការងារដែលមានលក្ខណៈអន្តរវិស័យ ដោយមានការសម្របសម្រួលពីក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- រៀបចំ បូកសរុប និងផ្តល់របាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម និងបញ្ហាប្រឈមជូនក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុកការកសាងធនធានមនុស្សឌីជីថល។

**ប្រការ១២.-**

ក្រុមការងារបច្ចេកទេសទទួលបន្ទុកការលើកកម្ពស់និងការជំរុញបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍ ត្រូវដឹកនាំដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ក្រុមការងារបច្ចេកទេសទទួលបន្ទុកការលើកកម្ពស់និងការជំរុញបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍ មានភារកិច្ចដូចខាងក្រោម៖

- ជំរុញនិងគាំទ្រដល់ការលើកកម្ពស់បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍
- ជំរុញការសិក្សាអំពីតម្រូវការក្នុងការវិនិយោគផ្នែកបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍
- ជំរុញការវិនិយោគផ្នែកបច្ចេកវិទ្យានិងអ្នកមានទេពកោសល្យផ្នែកបញ្ញាសិប្បនិម្មិត

- លើកកម្ពស់និងជំរុញការផ្ទេរបច្ចេកវិទ្យា
- ចូលរួមផ្តល់យោបល់និងរៀបចំកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថលពាក់ព័ន្ធនឹងការលើកកម្ពស់និងការជំរុញបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍
- ផ្តល់កិច្ចសហការជាមួយនឹងក្រុមការងារបច្ចេកទេសផ្សេងទៀត ក្នុងការជំរុញការងារដែលមានលក្ខណៈអន្តរវិស័យ ដោយមានការសម្របសម្រួលពីក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- រៀបចំ បូកសរុប និងផ្តល់របាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម និងបញ្ហាប្រឈមជូនក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុកការលើកកម្ពស់និងការជំរុញបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍។

**ប្រការ១៣.-**

ក្រុមការងារបច្ចេកទេសទទួលបន្ទុកសុវត្ថិភាពឌីជីថល សន្តិសុខសាយប័រ និងអភិបាលកិច្ចទិន្នន័យ ត្រូវដឹកនាំដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ក្រុមការងារបច្ចេកទេសទទួលបន្ទុកសុវត្ថិភាពឌីជីថល សន្តិសុខសាយប័រ និងអភិបាលកិច្ចទិន្នន័យ មានភារកិច្ចដូចខាងក្រោម៖

- ជំរុញនិងគាំទ្រដល់ការការពារសុវត្ថិភាពឌីជីថលនិងសន្តិសុខសាយប័រ ព្រមទាំងអភិបាលកិច្ចទិន្នន័យ
- ជំរុញការបន្សីស្តង់ដាសន្តិសុខសាយប័រនិងការការពារសន្តិសុខសាយប័រក្នុងក្របខណ្ឌទ្វេភាគី តំបន់ និងសកល
- ជំរុញកិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែនពាក់ព័ន្ធនឹងសុវត្ថិភាពឌីជីថល សន្តិសុខសាយប័រ និងអភិបាលកិច្ចទិន្នន័យ
- ជំរុញនិងបង្កើនការការពារទិន្នន័យបុគ្គល
- ជំរុញការរៀបចំក្របខណ្ឌនៃការបែងចែកប្រភេទទិន្នន័យ
- ជំរុញការការពារសុវត្ថិភាពតាមប្រព័ន្ធអនឡាញ
- សិក្សាអំពីតម្រូវការច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតពាក់ព័ន្ធនឹងកូដប្រភព (Source code)
- សិក្សានិងរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រគាំទ្រដល់លំហូរទិន្នន័យឆ្លងកាត់ព្រំដែន
- ចូលរួមផ្តល់យោបល់និងរៀបចំកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថលពាក់ព័ន្ធនឹងការការពារសុវត្ថិភាពឌីជីថល សន្តិសុខសាយប័រ និងអភិបាលកិច្ចទិន្នន័យ
- ផ្តល់កិច្ចសហការជាមួយនឹងក្រុមការងារបច្ចេកទេសផ្សេងទៀត ក្នុងការជំរុញការងារដែលមានលក្ខណៈអន្តរវិស័យ ដោយមានការសម្របសម្រួលពីក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- រៀបចំ បូកសរុប និងផ្តល់របាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម និងបញ្ហាប្រឈមជូនក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល

- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុកសុវត្ថិភាពឌីជីថល សន្តិសុខសាយប័រ និងអភិបាលកិច្ចទិន្នន័យ។

**ប្រការ១៤.-**

ក្រុមការងារបច្ចេកទេសទទួលបន្ទុកហេដ្ឋារចនាសម្ព័ន្ធនិងការតភ្ជាប់ឌីជីថល ត្រូវដឹកនាំដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ក្រុមការងារបច្ចេកទេសទទួលបន្ទុកហេដ្ឋារចនាសម្ព័ន្ធនិងការតភ្ជាប់ឌីជីថល មានភារកិច្ចដូចខាងក្រោម៖

- ជំរុញនិងគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងការតភ្ជាប់ឌីជីថលដែលមានគុណភាព
- បង្កើនភាពងាយតភ្ជាប់បណ្តាញហេដ្ឋារចនាសម្ព័ន្ធឌីជីថលនិងតម្លៃសមរម្យ
- សិក្សាអំពីតម្រូវការច្បាប់និងលិខិតបទដ្ឋានគតិយុត្តគាំទ្រនានា
- ចូលរួមផ្តល់យោបល់និងរៀបចំកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថលពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងការតភ្ជាប់ឌីជីថល
- ផ្តល់កិច្ចសហការជាមួយនឹងក្រុមការងារបច្ចេកទេសផ្សេងទៀត ក្នុងការជំរុញការងារដែលមានលក្ខណៈអន្តរវិស័យ ដោយមានការសម្របសម្រួលពីក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- រៀបចំ បូកសរុប និងផ្តល់របាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម និងបញ្ហាប្រឈមជូនក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្តាល
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុកហេដ្ឋារចនាសម្ព័ន្ធនិងការតភ្ជាប់ឌីជីថល។

**ប្រការ១៥.-**

សមាសភាពជាក់ស្តែងនៃក្រុមការងារបច្ចេកទេសនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**ប្រការ១៦.-**

ក្រុមការងារបច្ចេកទេសនីមួយៗ ត្រូវប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារនីមួយៗ។ ក្នុងករណីដែលប្រធានក្រុមការងារអវត្តមានឬមានករណីចាំបាច់ ប្រធានក្រុមការងារអាចផ្ទេរសិទ្ធិជូនអនុប្រធានណាមួយដើម្បីដឹកនាំកិច្ចប្រជុំ។

សមាជិកក្រុមការងារបច្ចេកទេសនីមួយៗ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ឬអនុប្រធានក្រុមការងារណាមួយក្នុងករណីដែលប្រធានក្រុមការងារអវត្តមានឬមានករណីចាំបាច់។

**ប្រការ១៧.-**

ក្រុមការងារបច្ចេកទេសនីមួយៗ អាចអញ្ជើញថ្នាក់ដឹកនាំនិងមន្ត្រីក្រោមឱវាទនៃក្រសួង-ស្ថាប័ននិងអង្គភាពពាក់ព័ន្ធផ្សេងទៀតនៃរាជរដ្ឋាភិបាលចូលរួមក្នុងកិច្ចប្រជុំពិនិត្យនិងពិភាក្សាតាមការចាំបាច់។

**ប្រការ១៨.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ៩ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ